កម្មវិធី PECSA នឹងផ្តល់មូលនិធិដល់ អង្គការសង្គមស៊ីវិល និង អ្នកដើរតួនាទី ផ្សេងៗទៀតដែលមិនមែនជាស្ថាប័នរដ្ឋ និងដែលបានចូលរួមយ៉ាងសកម្មរួចមក ហើយនៅក្នុងសកម្មភាពដើម្បីជំរុញឱ្យមានតម្លាភាព ការទទួលខុសត្រូវ និង អភិបាលកិច្ច ក្នុងប្រទេសកម្ពុជា រី កំពុងរៀបចំផែនការដើម្បីអនុវត្តសកម្មភាព បែបនេះ ។

## តើ PECSA ផ្តោតលើវិស័យអ្វីខ្លះ?

PECSA នឹងពង្រឹងសមត្ថភាពលើការទទួលខុសត្រូវសង្គម ដោយផ្តោតលើ វិស័យអាទិភាពដូចខាងក្រោម :

- បង្កើនប្រសិទ្ធភាពនៃសេវាសាធារណៈ
- ត្រួតពិនិត្យចំណាយសាធារណៈ និង លើកកំពស់ការទទួលខុសត្រូវក្នុងកិច្ចការនេះ
- ពង្រឹងការគ្រប់គ្រងធនធានធម្មជាតិរបស់ប្រទេសកម្ពុជា
- ពង្រឹងអភិបាលកិច្ចលើវិស័យឯកជន
- ពង្រឹងប្រព័ន្ធផ្សព្វផ្សាយ ដែលជាឧបករណ៏នាំឱ្យមានអភិបាលកិច្ចល្អ និង
- សេចក្តីបារម្ភដែលបន្ទាន់ និង ពាក់ព័ន្ធដទៃទៀតរបស់អ្នកអនុវត្តការងារ ទទួលខុសត្រូវសង្គម ក្នុងប្រទេសកម្ពុជា ។

## តើ PECSA មានន័យដូចម្តេចចំពោះ ធនាគារពិភពលោក និងចំពោះប្រទេសកម្ពុជា?

បញ្ហាអភិបាលកិច្ចត្រូវបានកំនត់ថាជាឧបសគ្គចំបងក្នុងការកាត់បន្ថយភាពក្រីក្រ ដើម្បីឱ្យមាននិរន្តភាពក្នុងប្រទេសកម្ពុជាក្រោមយុទ្ធសាស្ត្រផ្តល់ជំនួយដល់ ប្រទេសរបស់ធនាគារពិភពលោក សម្រាប់ឆ្នាំហិរញ្ញវត្ថុ ២០០៥ ដល់ ២០០៨។ យុទ្ធសាស្ត្រផ្តល់ជំនួយដល់ប្រទេស របស់ធនាគារពិភាពលោក មានគោលបំណងជួយអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ដែលផ្តល់ការវិនិច្ឆ័យ ត្រឹមត្រូវលើឧបសគ្គក្នុងការអភិវឌ្ឍន៏ប្រទេសកម្ពុជា ជាពិសេសអភិបាលកិច្ចល្អ ដែលជាចំណុចស្នូលដ៏សំខាន់ និង តារាងសកម្មភាពលំអិតសំរាប់ដោះស្រាយ បញ្ហាទាំងនេះ ។ធនាគារពិភពលោក និង ដៃគូម្ចាស់ជំនួយដទៃទៀត បានគាំទ្រការបង្កើតផែនការថ្មីរបស់រដ្ឋាភិបាលដែលមានរយៈពេលប្រាំឆ្នាំ គឺពីឆ្នាំ២០០៦ ដល់ឆ្នាំ២០១០ ដែលមានឈ្មោះថា ផែនការយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍន៏ជាតិ ១ណ្យឧភឋ ហើយឥឡូវនេះធនាគារពីភពលោក កំពុងគាំទ្រដល់ការអនុវត្តន៏ ការត្រួតពិនិត្យ និង ការវាយតម្លៃ លើផែនការនេះ ។

នាទសវត្សរ៏កន្លងទៅ ជំនួយដែលខ្វះការសម្របសម្រួល និងដែលមានការដឹកនាំ ពីម្ចាស់ជំនួយ តែងនាំឱ្យការវិវឌ្ឍន៏របស់អភិបាលកិច្ចល្អមានភាពយឺតយ៉ាវ ។ការបង្កើនឱ្យមានការទទួលស្គាល់ទៅលើបញ្ហានេះ នាំឱ្យមានការព្រមព្រៀងគ្នារ វាងរដ្ឋាភិបាល និង ម្ចាស់ជំនួយទៅលើរបៀបវារៈក្នុងការបង្កើតឱ្យមាននូវ សុខុដុមនីយកម្ម និង ការកែសំរួល ដែលក្នុងនោះ ក្រុមធនាគារពិភពលោក បានរួមចំណែកយ៉ាងសកម្ម ។ វាគឺជាគោលការណ៏ស្នូល នៃយុទ្ធសាស្ត្រផ្តល់ជំនួយរបស់ធនាគារពិភពលោក ដែលត្រូវធ្វើការតាមរយៈយុទ្ធសាស្ត្រភាពជាដៃគូ ដើម្បីកាត់បន្ថយតម្លៃចំណាយលើការអនុវត្តន៏ការងារ បង្កើនការទទួលខុសត្រូវ និង គាំទ្រដល់ការអភិវឌ្ឍន៏សមត្ថភាពស្នូលរបស់រដ្ឋាភិបាល ។

**សំរាប់ព័ត៏មានបន្ថែមអំពីកម្មវិធី PECSA សូមទាក់ទង :**

ធនាគារពិភពលោក ការិយាល័យប្រចាំនៅប្រទេសកម្ពុជា
អគារលេខ ១១៣ មហាវិថីនរោត្តម
ក្រុងភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទលេខ : (៨៥៥_២៣) ២១៧ ៣០១/៣០៤
ទូរសារលេខ: (៨៥៥_២៣) ២១០ ៥០៤/៣៧៣

# កម្មវិធី ពង្រឹងសមត្ថភាព ដើម្បីការទទួល ខុសត្រូវសង្គម (PECSA)

## ធ្វើការរួមគ្នាដើម្បីការទទួលខុសត្រូវកិច្ចការសង្គម

## តើ PECSA ជាអ្វី?

កម្មវិធីពង្រឹងសមត្ថភាពដើម្បីការទទួលខុសត្រូវសង្គម (PECSA) គឺជាកម្មវិធី ដែលផ្តល់មូលនិធិដោយធនាគារពិភពលោកក្នុងប្រទេសកម្ពុជា ហើយអនុម័តដោយក្រសួងមហាផ្ទៃ។ កម្មវិធីនេះឆ្លើយតបទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ ដើម្បីជួយប្រជាពលរដ្ឋកម្ពុជាឱ្យមានលទ្ធភាពជួយដល់រដ្ឋាភិបាលរបស់ពួកគេបំពេញភារៈកិច្ចឱ្យកាន់តែមានប្រសិទ្ធភាព និង ការទទួលខុសត្រូវ PECSA ខិតខំលើកកំពស់សមត្ថភាពរបស់អង្គការសង្គមស៊ីវិល តាមរយៈសកម្មភាពដូចខាងក្រោម :

- **ក)** ផ្តល់ការបណ្តុះបណ្តាលដល់អង្គការសង្គមស៊ីវិលក្នុងការប្រើប្រាស់វិធីសាស្ត្រ និង ឧបករណ៍សំរាប់អនុវត្តការងារទទួលខុសត្រូវសង្គម
- **ខ)** កែសម្រួលការអនុវត្តន៍ការទទួលខុសត្រូវសង្គមដែលមានលក្ខណៈជាសាកល ឱ្យស្របទៅតាមបរិបទប្រទេសកម្ពុជា
- **គ)** ផ្តល់មូលនិធិជំនួយដើម្បីអភិវឌ្ឍន៍ និង អនុវត្តសាកល្បងលើការងារទទួលខុសត្រូវសង្គម និង
- **ឃ)** គាំទ្រ និង លើកទឹកចិត្ត ឱ្យមានការចែករំលែកព័ត៌មាន និង ការកសាងបណ្តាញ ក្នុងចំណោមអ្នកអនុវត្តន៍ការងារទទួលខុសត្រូវសង្គម។

### សមាសធាតុសំខាន់ទាំងបួនរបស់ PECSA :

សកម្មភាពក្នុងវិស័យសំខាន់ៗទាំងបួនរបស់ PECSA រួមមានដូចតទៅ :

### I. ការបណ្តុះបណ្តាល និង ការកសាងសមត្ថភាព

**ក)** ផ្តល់ការគាំទ្រ ផ្នែកបណ្តុះបណ្តាល និង ការបង្ហាត់ បង្រៀនដល់តួអង្គ ក្នុងសង្គមស៊ីវិល (រួមមាន អ្នកដឹកនាំ និង សមាជិក NGOs, អង្គការដែលមានមូលដ្ឋាននៅតាមសហគមន៏(CBOs), ប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ និង សហជីព) ដើម្បីអភិវឌ្ឍន៏ជំនាញរបស់ពួកគាត់ លើវិធីសាស្ត្រ និងឧបករណ៏សំរាប់អនុវត្តការងារទទួលខុសត្រូវសង្គម ដោយរាប់បញ្ចូល នូវប្រធានបទមួយចំនួនខាងក្រោម រួមជាមួយនិងប្រធានបទដទៃទៀតៈ

- ការទទួលបាននូវព័ត៌មានសាធារណៈ
- ពង្រឹងភាពជាអ្នកដឹកនាំនៅសហគមន៏ ដើម្បីការចូលរួមរបស់ពលរដ្ឋ
- ការតស៊ូមតិដោយផ្អែកលើភស្តុតាង
- ការប្រាស្រ័យទាក់ទង និង ទំនាក់ទំនងជាមួយសារព័ត៌មានការ
- ពិភាក្សាប្រកបដោយការស្ថាបនាទៅលើគោលនយោបាយ និង ផែនការ សាធារណៈ
- ការត្រួតពិនិត្យ និង ចូលរួមចំណែកក្នុងការរៀបចំថវិកា
- ការតាមដានចំណូល និង ចំណាយសាធារណៈ
- ការត្រួតពិនិត្យ និង វាយតម្លៃសេវាសាធារណៈ
- ការបង្កើតទំនាក់ទំនង និង ភាពជាដៃគូ រវាងសង្គមស៊ីវិល និង រដ្ឋ

**ខ)** រៀបចំទស្សនកិច្ចសិក្សាសម្រាប់អ្នកដឹកនាំអង្គការសង្គមស៊ីវិលដើម្បីរៀនសូត្រអំពីវិធីសាស្ត្រក្នុងការប្រើប្រាស់ឧបករណ៏សំរាប់ការអនុវត្តន៏ជាក់លាក់ក្នុងការងារទទួលខុសត្រូវសង្គមក្នុងប្រទេសដទៃទៀត និង ផ្តល់អាហារូបករណ៏ដើម្បីពង្រីកការយល់ដឹងរបស់ពួកគេ លើការអនុវត្តន៏ វិធីសាស្ត្រ និង ឧបករណ៏ជាក់លាក់ ក្នុងការងារទទួលខុសត្រូវសង្គមទាំងនៅក្នុង និងក្រៅប្រទេសកម្ពុជា។

### II. ការរៀនសូត្រតាមរយៈការអនុវត្តន៏សកម្មភាព និងការបង្កើតឧបករណ៏

**ក)** សាកល្បងយន្តការបង្កើតទីផ្សាប្រកួតប្រជែង Development Marketplace ដើម្បីផ្តល់មូលនិធិជំនួយ សំរាប់សកម្មភាព ពង្រឹងអភិបាលកិច្ចល្អតាមរយៈការអនុវត្តន៏ការទទួលខុសត្រូវសង្គម។

**ខ)** ផ្តល់ជំនួយខ្នាតតូចដើម្បី បង្កើត សាកល្បង និង កែសម្រួលឧបករណ៏ សំរាប់អនុវត្តការងារទទួលខុសត្រូវសង្គម ឱ្យស្របទៅតាមបរិបទ របស់ប្រទេសកម្ពុជា ដោយរាប់បញ្ចូលទាំងការត្រួតពិនិត្យលើការអនុវត្តន៏របស់ពួកគេ ការផ្សព្វផ្សាយពីលទ្ធផល និងប្រើប្រាស់លទ្ធផលទាំងនោះ ជាករណីសិក្សានៅក្នុងគំនិតផ្តួចផ្តើមសំរាប់ការកសាងសមត្ថភាពបន្ថែម។

### III. ការកសាងបណ្តាញ និង មជ្ឈមណ្ឌលឯកសារ

**ក)** កសាងបណ្តាញអ្នកអនុវត្តន៏ការងារទទួលខុសត្រូវសង្គម អនុវត្តសាកល្បងនូវសកម្មភាពថ្មីៗដើម្បីពង្រឹងអភិបាលកិច្ច ផ្លាស់ប្តូរបទពិសោធន៏ និង ពិភាក្សាអំពីបញ្ហាដែលទាក់ទងទៅនឹងអភិបាលកិច្ច ជាមួយស្ថាប័នរដ្ឋ។

**ខ)** បង្កើតវែបសាយ និង មជ្ឈមណ្ឌលឯកសារ ដែលផ្តល់ព័ត៌មានអំពីការអនុវត្តន៏ជាអន្តរជាតិក្នុងការងារទទួលខុសត្រូវសង្គម ដែលរួមមាន ឯកសារគន្លឹះ ឈ្មោះរបស់អ្នកជំនាញផ្នែកការងារទទួលខុសត្រូវសង្គម សម្ភារៈបណ្តុះបណ្តាល និងករណីសិក្សា ។ល។

### IV. ការត្រួតពិនិត្យ ការវាយតម្លៃ និងការរៀនសូត្រ

**ក)** ត្រួតពិនិត្យលើសមិទ្ធផល និង វាយតម្លៃលទ្ធផល និង ផលប៉ះពាល់នៃ សកម្មភាពរបស់កម្មវិធី ដោយរាប់បញ្ចូលទាំងការកំណត់ និងការរៀបចំឯកសារ ស្តីពីមេរៀនជាបទពិសោធន៏ដែលពាក់ព័ន្ធ ព្រមទាំងការអនុវត្តន៏ ល្អៗជាច្រើនទៀត ដើម្បីផ្តល់ជាព័ត៌មានដល់គំរោងអភិបាលកិច្ចមូលដ្ឋាន(DFGG) ដែលត្រូវបានស្នើឡើង។

**ខ)** ធ្វើការសិក្សាដើម្បីលើកកំពស់ការអនុវត្តន៏ការទទួលខុសត្រូវសង្គម ដោយ រាប់បញ្ចូល ការវាយតម្លៃលើ តម្រូវការក្នុងការកសាងសមត្ថភាព ដើម្បីអនុវត្តការងារទទួលខុសត្រូវសង្គម ការវិភាគលើបញ្ហា ដែលពាក់ព័ន្ធ ទៅនឹងអភិបាលកិច្ច ការវាយតម្លៃលើការអនុវត្តន៏ការងារ ទទួលខុសត្រូវសង្គមជាក់លាក់ណាមួយ និង ការវិភាគលើកត្តារាំងស្ទះក្នុងការអនុវត្តន៏ ការទទួលខុសត្រូវសង្គម។

## តើនរណាជាដៃគូដែលប្រកបដោយសក្តានុពលរបស់ PECSA ?

កម្មវិធី PECSA នឹងខិតខំឱ្យអស់ពីសមត្ថភាពរបស់ខ្លួន ដើម្បីធ្វើឱ្យកម្មវិធីនេះ ប្រកបដោយអត្ថន័យ និង ផ្តល់ជាអត្ថប្រយោជន៏ ដល់ប្រជាជនកម្ពុជា តាមដែលខ្លួនអាចធ្វើទៅបាន តាមរយៈការគាំទ្រ និងភ្ជាប់ទំនាក់ទំនងដោយផ្ទាល់ជាមួយ ក្រុមសង្គមស៊ីវិលផ្សេងៗដូចជាៈ អង្គការដែលមានមូលដ្ឋាននៅតាមសហគមន៏ (CBOs) អង្គការមិនមែនរដ្ឋាភិបាល (NGOs) សមាគមប្រជាពលរដ្ឋ សហជីព និងប្រព័ន្ធផ្សព្វផ្សាយដែលធ្វើការនៅថ្នាក់មូលដ្ឋាន ថ្នាក់ខេត្ត និង ថ្នាក់ជាតិ។